# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ០13/០៣ ក.ប.ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៣

## ជំរាបមក

## លោក ឡេង សេង ប្រធានគណបក្សកសាងជាតិ

**កម្មវត្ថុ** : អំពីបណ្តឹងតវ៉ាលើសេចក្តីប្រកាសបដិសេធការចុះបញ្ជីគណបក្សកសាងជាតិ ឈរឈ្មោះបោះឆ្នោត

**យោង** - សេចក្តីសំរេចរបស់គ.ជ.ប លេខ ០៥.៧៩៧/០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣

- ពាក្យបណ្តឹងលេខ ០២៩/០៣ គកជ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ របស់គណបក្សកសាងជាតិ

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញ ពុំអាចអនុគ្រោះតាមសំណូមពររបស់លោកបានទេ ពីព្រោះការដែលមិនបានបំពេញបន្ថែមល័ក្ខខ័ណ្ឌទី១០ នៃមាត្រា៣៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះ ឱ្យទាន់ក្នុងរយៈពេលកំណត់ដោយច្បាប់ ត្រូវចាត់ទុកថាគណបក្សលោកបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌចុងក្រោយនៃ មាត្រា ៤០ថ្មី នៃព្រះរាជក្រមនស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញ

ប៊ិន ឈិន